**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
លេខ: ០០១/១៨ សរពង.ពឃហ

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង៨ និង៣០នាទីព្រឹក នៅវិមានសន្តិភាព មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងអាណត្តិទី៥ ដើម្បីឆ្លង៖

**១- សេចក្ដីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។**

**២- របាយការណ៍ស្ដីពីលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យឡើងវិញ នូវគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងហ្សឺណែវប្រទេសស្វីស**

**៣- បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័ននីតិប្បញ្ញត្តិលើ៖ កិច្ចព្រមព្រៀងស្ដីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ -វៀតណាម។

ក្រោយពីបានស្ដាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្ដូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានសម្រេចអនុម័ត៖

**១- សេចក្ដីព្រាងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។**

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០០៤។ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើននៅក្នុងការងារនេះ ជាពិសេសសម្រេចបានជាសារវន្តនូវជំហានទី១ គឺ «ភាពជឿទុកចិត្តបាននៃថវិកា» និងជំហានទី២ គឺ «គណនេយ្យភាពហិរញ្ញវត្ថុ»។ បច្ចុប្បន្ននេះការអនុវត្តជំហានទី៣ គឺ «ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ» នឹងត្រូវបញ្ចប់នៅឆ្នាំ២០២០ មុននឹងបន្តអនុវត្តជំហានទី៤គឺ «គណនេយ្យភាពសមិទ្ធកម្ម» ចាប់ពីឆ្នាំ២០២១ ទៅដល់ ឆ្នាំ២០២៥។

ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ បានបើកច្រកឱ្យរាជរដ្ឋាភិបាល ចាប់ផ្ដើមអនុវត្តសាកល្បងដោយថេរៗនូវថវិកាកម្មវិធីជាបណ្ដើរៗ។ ផ្អែកតាមឯកសារទស្សនៈទានស្ដីពី *«ទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ថវិកានៅកម្ពុជា ឆ្នាំ ២០១៣ -២០២០»* ប្រព័ន្ធថវិកានឹងត្រូវផ្លាស់ប្ដូរជាបណ្ដើរៗពីប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅប្រព័ន្ធថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម និងវិមជ្ឈការនៅក្នុងឆ្នាំ២០២០។

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥ រៀបចំឡើងផ្តោតជាសំខាន់ចំពោះ៖ ១.ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា ដោយឈរលើមូលដ្ឋានសំខាន់ៗ និងច្បាស់លាស់ជាពិសេស "ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម" ២.យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាជាតិ និង ៣.ផែនទីចង្អុលផ្លូវឆ្ពោះទៅកាន់គោលដៅយុទ្ធសាស្ត្រឆ្នាំ២០២៥។

ឯកសារយុទ្ធសាស្ត្រនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកាពហុឆ្នាំជាអាទិ៍ ឈានទៅធ្វើសាមញ្ញកម្មក្របខ័ណ្ឌ និងនីតិកម្មនៃការត្រួតពិនិត្យការបើកផ្តល់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ចំណែកការទូទាត់សាច់ប្រាក់នឹងធ្វើតាមរយៈការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិច (E-Transfer)។

**២- របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យឡើងវិញ នូវគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីក្រុងហ្សឺណែវប្រទេសស្វីស**

សម្រាប់ការត្រួតពិនិត្យឡើងវិញលើគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ មានគោលដៅត្រួតពិនិត្យវាយតម្លៃឡើងវិញអំពីវឌ្ឍនភាពនៃស្ថានភាពសេដ្ឋកិច្ចសង្គមកម្ពុជា និងការកែទម្រង់ពាក់ព័ន្ធនានា ក្រោយពេលដែលព្រះរាជាណាចក្រកម្ពុជាបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤។ ការត្រួតពិនិត្យឡើងវិញនេះត្រូវបានធ្វើលើកទី១នៅឆ្នាំ២០១១។

នៅក្នុងរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំត្រួតពិនិត្យឡើងវិញ ដោយផ្តោតលើ៖ ១.វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ២.ប្រាក់ចំណូល សុខុមាលភាព និងភាពងាយរងគ្រោះ ៣.ការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងទីផ្សារអន្តរជាតិ (ដោយគិតចាប់តាំងពីការកសាងបន្ថែមនិងធ្វើឱ្យប្រសើរឡើងនូវបទដ្ឋានគតិយុត្តិនិងច្បាប់ ការកាត់បន្ថយចំណាយ ដើម្បីអនុលោមតាមបទដ្ឋានច្បាប់ និងនីតិវិធីរបស់រាជរដ្ឋាភិបាល សេវាសាធារណៈ និងបែបបទរដ្ឋបាល រហូតដល់ការគ្រប់គ្រងហានិភ័យជាដើម តាមតម្រូវការអង្គការពាណិជ្ជកម្មពិភពលោក។) និង ៤.ពាណិជ្ជកម្ម អភិវឌ្ឍន៍ និងដៃគូអភិវឌ្ឍន៍។

**៣- បញ្ហាផ្សេងៗ៖** អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបានអនុម័តបញ្ជូនទៅសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិនូវកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ -វៀតណាម។

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីបាន៖

- ប្រកាសពន្យារ១០ថ្ងៃទៀត សម្រាប់ការតាំងពិព័រណ៍សមិទ្ធផលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី២ ដែលមានទីតាំងក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុញ្ញាតឱ្យប្រជាពលរដ្ឋ និងសិស្ស-និស្សិត បានចូលទស្សនា។
- ប្រកាសបង្កើត និងអនុវត្តមូលនិធិត្រីចក្រយាន (ស៊ីក្លូ) ចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១៨ តទៅ ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង ៥០នាទី។

ថ្ងៃសុក្រ ១១ រោច ខែបុស្ស ឆ្នាំ រកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ទី១២ ខែមករា ឆ្នាំ ២០១៨